# គណៈកម្មការទន្លេមេគង្គ

ប្រអប់សំបុត្រលេខ ៦១០១ ទីក្រុងវៀងច័ន្ទ ០១០០០ សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ទូរស័ព្ទលេខ ៨៥៦-២១ ២៦៣២៦៣   ទូរសារលេខ ៨៥៦-២១ ២៦៣២៦៤

អ៊ីម៉ែល: mrcs@mrcmekong.org  វិបសាយ: www.mrcmekong.org


## ព័ត៌មានសំរាប់ប្រព័ន្ធផ្សព្វផ្សាយ

## គណៈកម្មការទន្លេមេគង្គ ធ្វើទស្សនកិច្ចទៅកាន់ទំនប់វារីអគ្គិសនីប្រទេសចិន ហើយនឹងពិភាក្សាកិច្ចសហប្រតិបតិការ នាពេលអនាគតជាមួយចិន

៧ មិថុនា ២០១០ — វៀងចន្ទ័, សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

សំរាប់ការចេញផ្សាយបន្ទាន់

គណៈប្រតិភូនៃប្រទេសទន្លេមេគង្គក្រោម និងប្រតិភូមកពីលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ នឹងធ្វើទស្សនកិច្ចទៅកាន់ទំនប់វារីអគ្គិសនីប្រទេសចិននៅសប្តាហ៍នេះជាលើកទីមួយ ហើយបន្ទាប់មកនឹងជួបប្រជុំនៅទីក្រុងប៉េកាំង ដើម្បីពិភាក្សាអំពីកិច្ចសហប្រតិបតិការរវាងចិនជាមួយនឹងគណៈកម្មការទន្លេមេគង្គ។ ដំណើរទស្សនកិច្ចនេះ ត្រូវបានរៀបចំឡើង បន្ទាប់ពីចិនបានបង្ហាញពីការប្តេជ្ញាចិត្តក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគណៈកម្មការទន្លេមេគង្គនៅឯកិច្ចប្រជុំកំពូលលើកដំបូងរៀបចំដោយគណៈកម្មការទន្លេមេគង្គនៅប្រទេសថៃកាលពីដើមខែមេសាកន្លងមក។

មន្ត្រីតំណាងរដ្ឋាភិបាលមកពីប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម អមដំណើរដោយមន្ត្រីរដ្ឋាភិបាលចិន នឹងធ្វើដំណើរទស្សនកិច្ចទៅកាន់ទីតាំងទំនប់វារីអគ្គិសនីពីររបស់ចិននៅទន្លេមេគង្គលើខេត្តយូណាននៅដើមសប្តាហ៍នេះ។ គណៈកម្មការទន្លេមេគង្គ និយាយថា គណៈកម្មការ នឹងបញ្ជូនគណៈប្រតិភូមួយក្រុមរបស់ខ្លួនទៅកាន់កិច្ចប្រជុំជាមួយរដ្ឋាភិបាលចិននៅទីក្រុងប៉េកាំងប្រយោជន៍ដើម្បីពិភាក្សា អំពីជម្រើសមួយចំនួនសំរាប់បង្កើនការចូលរួមរបស់ប្រទេសចិននៅក្នុងសកម្មភាពកម្មវិធីនានារបស់គណៈកម្មការទន្លេមេគង្គ ដែលជាស្ថាប័នមួយមានតួនាទីជួយសម្របសម្រួលប្រទេសសមាជិកដើម្បីគ្រប់គ្រងធនធានទឹកនៅអាងទន្លេមេគង្គក្រោម។

ប្រទេសចិន ជាដៃគូសន្ទនារបស់គណៈកម្មការទន្លេមេគង្គ ចាប់តាំងពីឆ្នាំ ១៩៩៦ មក ហើយបានធ្វើកិច្ចសហប្រតិបត្តិការជាមួយនឹងគណៈកម្មការទន្លេមេគង្គទៅលើវិស័យមួយចំនួន ដូចជាការផ្តល់ព័ត៌មានជលសាស្ត្រនៅរដូវទឹកតំឡើង។ គណៈកម្មការទន្លេមេគង្គនិយាយថា ការផ្តល់ព័ត៌មាននេះបានដើរតួនាទីសំខាន់ជួយដល់ការព្យាករទឹកជំនន់។ នៅចុងខែនេះ ប្រទេសចិន នឹងទទួលធ្វើជាម្ចាស់ផ្ទះ

រៀបចំវគ្គបណ្តុះបណ្តាលមួយស្តីអំពីការគ្រប់គ្រងទឹកជំនន់ និងការកាត់បន្ថយគ្រោះមហន្តរាយសំរាប់បុគ្គលិកភ្នាក់ងាររដ្ឋាភិបាលមកពីប្រទេសទន្លេមេគង្គក្រោម។

លោក ជេរេមី ប៊ឺត ប្រធាន លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និយាយថា "ទស្សនកិច្ចទៅកាន់ទំនប់វារីអគ្គិសនីចិននេះ ត្រូវបានធ្វើឡើងក្រោយពីមានទស្សនកិច្ចពីរលើករួចមកហើយរបស់ក្រុមជំនាញការផ្នែកធ្វើម៉ូដែល និងផ្នែកវារីអគ្គិសនី របស់គណៈកម្មការទន្លេមេគង្គ ជាមួយនឹងមន្ត្រីរដ្ឋាភិបាលចិនទៅកាន់ខេត្តយូណាន។ ប្រតិភូទស្សនកិច្ច បានផ្តល់នូវមតិយោបល់យ៉ាងសំខាន់ដល់ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់ផ្នែកបរិស្ថាននៃគម្រោងសាងសាង់ទំនប់វារីអគ្គិសនីនៅទន្លេមេនៃទន្លេមេគង្គក្រោម។ នេះគឺជាឧទាហរណ៍មួយទៀតបង្ហាញពីកិច្ចសហប្រតិបត្តិការកាន់តែរឹងមាំ ហើយនឹងឈានទៅដល់ការស្វែងយល់កាន់តែប្រសើរជាងមុនអំពីផលប៉ះពាល់នៃការអភិវឌ្ឍនៅទន្លេមេគង្គលើមកលើទន្លេមេគង្គក្រោម។"

លោក ជេរេមី ប៊ឺត និយាយបន្ថែមទៀតថា "តាមរយៈការប៉ាន់ប្រមាណនេះ គណៈកម្មការទន្លេមេគង្គ នឹងធ្វើការផ្សព្វផ្សាយទាំងផលអវិជ្ជមាន និងកាលានុវត្តភាពនៃការអភិវឌ្ឍផ្នែកវារីអគ្គិសនីនៅតាមទន្លេមេនៃទន្លេមេគង្គ។ "

គណៈកម្មការទន្លេមេគង្គ និយាយថាដំណើរទស្សនកិច្ចទៅកាន់ទំនប់វារីអគ្គិសនី សៀវ វ៉ាន់ និងទំនប់ជីង ហុង នេះ ជានិមិត្តរូបមួយបង្ហាញពីទំនាក់ទំនងកាន់តែជិតស្និទ្ធ ដែលនឹងអាចឈានទៅដល់ការចែករំលែកព័ត៌មានកាន់តែច្រើនអំពីផែនការ និងព័ត៌មានប្រតិបត្តិការទំនប់វារីអគ្គិសនី ព្រមទាំងកិច្ចសម្រុះសម្រួលការងាររួម ស្របទៅតាមអាណត្តិរបស់គណៈកម្មការទន្លេមេគង្គដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងឆ្នាំ ១៩៩៥។

លោក ជេរេមី ប៊ឺត និយាយថា "មន្ត្រីចិន បានផ្តល់អោយគណៈកម្មការទន្លេមេគង្គ នូវព័ត៌មានអំពីផែនការ និងគំនូរប្លង់នៃគំរោងវារីអគ្គិសនីនៅទន្លេមេគង្គលើ ហើយបានបញ្ជាក់បន្ថែមថាធារទឹកកំរិតអប្បបរមារបស់ទន្លេមេគង្គក្រោម នឹងមិនត្រូវបានកាត់បន្ថយទេ ហើយថា នឹងរក្សាគុណភាពទឹកតាមស្តង់ដារត្រឹមត្រូវ។"

លោក ជេរេមី ប៊ឺត និយាយបន្ថែមថា "ការប្តេជ្ញាចិត្តនេះ ស្រដៀងគ្នាទៅនឹងការប្តេជ្ញាចិត្តដែលធ្លាប់បានធ្វើកន្លងមកក្នុងចំណោមបណ្តាប្រទេសទន្លេមេគង្គក្រោម នៅក្រោមនីតិវិធីនានានៃកិច្ចព្រមព្រៀងឆ្នាំ ១៩៩៥ ស្តីអំពីកិច្ចសហប្រតិបត្តិការសំរាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃអាងទន្លេមេគង្គ។ កិច្ចសហប្រតិបត្តិការកាន់តែទូលំទូលាយរវាង គណៈកម្មការទន្លេមេគង្គជាមួយនឹងប្រទេសចិននឹងចាំបាច់ដើម្បីជួយប្រជាជនរស់នៅតាមអាងទន្លេមេគង្គក្រោមត្រៀមខ្លួនសំរាប់ការផ្លាស់ប្តូរបបលំហូរទឹកនាពេលអនាគត ដែលបណ្តាលមកពីទំនប់វារីអគ្គិសនី ព្រមទាំងកំរិតទឹកទន្លេកើនឡើងនៅរដូវប្រាំង និងការពូនផ្តុំនៃកំទេចកំណរនៅពេលដែលទំនប់ ចាប់ផ្តើមដំណើរការពេលលេញ។"

ការពិភាក្សាជាបន្តបន្ទាប់ជាច្រើនមកនេះ កើតឡើងបន្ទាប់ពីចិនបានប្រកាសនាពេលថ្មីៗនេះថា ខ្លួនប្តេជ្ញាចិត្ត នឹងបង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងគណៈកម្មការទន្លេមេគង្គ។

ប្រធានបទដែលត្រូវបានលើកឡើងនៅក្នុងសេចក្តីប្រកាសរួមដោយប្រមុខដឹកនាំប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គ នៅឯកិច្ចប្រជុំកំពូលលើកទីមួយនៅហួ ហ៊ីនកាលពីដើមខែមេសា ផ្តោតទៅលើវិស័យនាវាចរ ទេសចរ ការប៉ាន់ប្រមាណជាយុទ្ធសាស្ត្រអំពីផលប៉ះពាល់លើបរិស្ថាននៃវារីអគ្គិសនី ការការពារបរិស្ថាន ការប្រែប្រួលអាកាសធាតុ កសិកម្ម និងធារាសាស្ត្រ ការការពារគ្រោះទឹកជំនន់ និងការកាត់បន្ថយគ្រោះមហន្តរាយ និងកម្មវិធីផ្លាស់ប្តូរជំនាញការបច្ចេកទេស។

----------

**សំរាប់ព័ត៏មានបន្ថែម** សូមទាក់ទងលោក ដាមាន គាន ទីប្រឹក្សាផ្នែកទំនាក់ទំនងរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ តាមរយៈអ៊ីមែល damian@mrcmekong.org ទូរស័ព្ទលេខ (៨៥៦-២០) ៧៥២ ៧៥០០ ឬ លោក លីម ឃី មន្ត្រីផ្នែកទំនាក់ទំនងរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ តាមរយៈអ៊ីមែល khy@mrcmekong.org ទូរស័ព្ទលេខ (៨៥៦-២០) ៥៥២ ៨៧២៦ និង វ៉ិបសាយ www.mrcmekong.org